archive.today
webpage capture

Saved from https://www.vodkhmer.news/2021/01/22/workers-in-3-factories-go-on-strike/ search

no other snapshots from this url

25 Mar 2024 02:36:18 UTC

All snapshots from host www.vodkhmer.news

Webpage Screenshot

share download .zip report bug or abuse



# កម្មកររោងចក្រ៣ផ្សេងគ្នានៅភ្នំពេញនិងកំពង់ស្ពឺធ្វើកូដកម្មទាមទារអត្ថប្រយោជន៍ការងារ

ព័ត៌មានជាតិ ការងារ

លោក វណ្ណ វិចារ | ២២ មករា ២០២១ ម៉ោង ១៧:៣៣




កម្មករ-កម្មការិនីរោងចក្រកាត់ដេរសម្លៀកបំពាក់ Y&W ស្ថិតនៅភូមិព្រែកជ្រៃ សង្កាត់ស្ពានថ្ម ខណ្ឌដង្កោ បានប្រមូលផ្ដុំគ្នាតវ៉ានិងបិទផ្លូវលេខ២១៧ ទាមទារដំណោះស្រាយការងារ នៅព្រឹកថ្ងៃទី២១ ខែមករា ឆ្នាំ២០២១។ (ផន ចាន់រ៉េន)

កម្មកររោងចក្រយ៉ាងតិចណាស់ចំនួន៣នៅទីតាំងផ្សេងគ្នាក្នុងរាជធានីភ្នំពេញនិងខេត្តកំពង់ស្ពឺ បានធ្វើកូដកម្មទាមទារអត្ថប្រយោជន៍ការងាររៀងៗខ្លួន នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២០នេះ។

រោងចក្រដែលមានកម្មករធ្វើកូដកម្មនោះ រួមមាន រោងចក្រ Y&W, រោងចក្រ ខេនធើរេន (Centeren Apparel Co LTD,) និងក្រុមហ៊ុន ហ្វូលីដេឌីហ្សាញ។ រោងចក្រ Y&W ស្ថិតនៅតាមបណ្ដោយផ្លូវ២១៧ ក្នុងសង្កាត់ព្រែកជ្រៃ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដែលមានកម្មករតវ៉ាប្រមាណជាង៥០០នាក់។ រោងចក្រ ខេនធើរេន (Centeren Apperel Co LTD,) ស្ថិតនៅតាមបណ្ដោយផ្លូវវេងស្រេង សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ដែលមានកម្មករតវ៉ាប្រមាណជិត៤០០នាក់ ។ ក្រុមហ៊ុន ហ្វូលីដេឌីហ្សាញ ស្ថិតនៅឃុំព្រៃល្វា ស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានកម្មករតវ៉ាប្រមាណជិត៣០០នាក់។

ក្នុងចំណោមរោងចក្រទាំងបី មានកម្មកររោងចក្រចំនួន២នៅភ្នំពេញ ព្រមចូលធ្វើការវិញ ខណៈដែលកម្មកររោងចក្រមួយ នឹងបន្តធ្វើកូដកម្មនៅថ្ងៃស្អែកទៀត។

តំណាងកម្មកររោងចក្រ Y&W លោក ផាន់ បុរី ឱ្យដឹងថា កម្មកររោងចក្រ Y&W បានព្រមព្រៀងចូលធ្វើការវិញត្រឹមម៉ោង១២ថ្ងៃត្រង់ ថ្ងៃទី២២ ខែមករា បន្ទាប់ពីតវ៉ា២ថ្ងៃមកនោះ។

លោកបន្តថា ក្រុមហ៊ុនព្រមព្រៀងកំណត់កាលបរិច្ឆេទបើកប្រាក់អតីតភាពឆ្នាំ២០២០ និងប្រាក់អតីតភាពការងារមុនឆ្នាំ២០១៩ ឱ្យបានមុនថ្ងៃចូលឆ្នាំខ្មែរខាងមុខ ព្រមទាំងមិនកាត់ប្រាក់ខែកម្មករក្នុងរយៈពេលដែលកម្មករនាំគ្នាធ្វើកូដកម្មលើកនេះឡើយ។

> “ ប្រសាសន៍លោក ផាន់ បុរី៖ **«ការតវ៉ាកម្មករ២ថ្ងៃហ្នឹង បានសម្រេចលទ្ធផលភាគច្រើន ទើបពួកយើងចូលធ្វើការវិញ»។**

តំណាងកម្មករនៅរោងចក្រ ខេនធើរេន (Centeren Apperel Co LTD,) អ្នកស្រី ណុប បូផាន ឱ្យដឹងថា កម្មករបម្រើការងារនៅរោងចក្រនេះ បានសម្រេចចូលធ្វើការវិញនៅថ្ងៃទី២៣ ខែមករា បន្ទាប់ពីភាគីរោងចក្រព្រមព្រៀងតាមចំណុចមួយចំនួនដែលកម្មករទាមទារមកនោះ។

> “ ប្រសាសន៍អ្នកស្រី ណុប បូផាន៖ **«ខាងក្រុមហ៊ុនគេព្រមបើកប្រាក់ឱ្យពួកយើងបានទៀងទាត់ជាងមុន និងព្រមចរចាកំណត់ថ្ងៃបើកប្រាក់អតីតភាពការងារ។ ដូច្នេះពួកយើងព្រមចូលធ្វើការវិញ បើពួកគេក្រឡាស់ពាក្យ យើងនឹងចេញតវ៉ាជាថ្មីទៀត»។**

តំណាងសហជីពប្រចាំរោងចក្រ ហ្វូលីដេឌីហ្សាញ លោក ឱ សុផល ឱ្យដឹងថា កម្មករប្រមាណជាង៣រយនាក់ធ្វើកូដកម្មមួយព្រឹកថ្ងៃទី២២ ខែមករានេះ ដើម្បីទាមទារឱ្យរោងចក្របើកប្រាក់អតីតភាពការងារ គោរពសិទ្ធិកម្មករ និងទាមទារឱ្យរោងចក្រអនុញ្ញាតឱ្យតំណាងសហជីពចូលធ្វើការវិញ។ លោកថា ភាគីរោងចក្រមិនទាន់ឆ្លើយតបចំពោះការទាមទាររបស់កម្មករនៅឡើយ។

> “ លោក ឱ សុផល មានប្រសាសន៍ថា៖ **«កម្មករនឹងនៅតែធ្វើកូដកម្មបន្តទៀត បើសិនជានៅតែមិនមានដំណោះស្រាយ»។**

វិអូឌី មិនអាចទាក់ទងតំណាងរោងចក្រ ហ្វូលីដេឌីហ្សាញ ដើម្បីបំភ្លឺបញ្ហានេះបានទេ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១។

ប្រធានសហព័ន្ធសហជីពកម្ពុជា អ្នកស្រី យ៉ាង សុភ័ណ្ឌ មានប្រសាសន៍ថា កូដកម្មកើតឡើងភាគច្រើននៅក្នុងឆ្នាំថ្មីនេះ គឺពាក់ព័ន្ធនឹងការទាមទារប្រាក់អតីតភាពការងារ និងប្រាក់រំឭកអតីតភាពការងារ។ អ្នកស្រីបន្តថា កម្មករចេញតវ៉ាគឺដោយសារតែកម្មករគាត់រង់ចាំប្រាក់អតីតភាពការងាររយៈពេលយូរពេក ម្យ៉ាងទៀតក្រុមកម្មករយល់ថាពួកគាត់ត្រូវគេកេងប្រវ័ញ្ច។

> “ អ្នកស្រី យ៉ាង សុភ័ណ្ឌ និយាយថា៖ **«ខ្ញុំចូលរួមជជែកគ្នាជាមួយក្រុមហ៊ុនច្រើនគួរសមដែរ ដើម្បីដាក់ពាក្យសុំបើកប្រាក់អតីតភាពការងារ ក្រុមហ៊ុនភាគច្រើនគាត់ឆ្លើយថា បើរដ្ឋាភិបាលសម្រេចម៉េច គេធ្វើអ៊ីចឹង។ ខ្ញុំយល់ថា ខាងក្រុមហ៊ុនគេចាំធ្វើតាមក្រសួងការងារប៉ុណ្ណោះ»។**

ទាក់ទងនឹងបញ្ហាប្រាក់អតីតភាពការងារ ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ កាលពីថ្ងៃទី២១ ខែមករា បានជូនដំណឹងដល់ម្ចាស់រោងចក្រសហគ្រាសទាំងអស់ ត្រូវបើកប្រាក់រំឭកនិងប្រាក់ដំណាច់អតីតភាពការងារជូនកម្មករឡើងវិញ ក្រោយពីក្រុមកម្មករផ្ទុះការតវ៉ាជាបន្តបន្ទាប់នៅដើមឆ្នាំ២០២១នេះ។

ក្រសួងការងារបញ្ជាក់ថា ប្រាក់រំឭកអតីតភាពការងារមានមុនឆ្នាំ២០១៩ (ប្រសិនបើមាន) ដែលចៅកែនៅជំពាក់កម្មករនោះ ត្រូវបើកជូនកម្មករនៅឆ្នាំ២០២០ ដោយអនុវត្តទូរទាត់នៅក្នុងត្រីមាសទី១ និងត្រីមាសទី៣។ ចំណែកឯប្រាក់រំឭកអតីតភាពការងារមានមុនឆ្នាំ២០១៩នេះដែរ ដែលត្រូវបើកក្នុងឆ្នាំ២០២១ គឺត្រូវអនុវត្តទូរទាត់ជូនកម្មករក្នុងត្រីមាសទី២ និងទី៤៕

**រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម**

សូមបញ្ជាក់ថា គ្មានផ្នែកណាមួយនៃអត្ថបទ រូបភាព សំឡេង និងវីដេអូទាំងនេះ អាចត្រូវបានផលិតឡើងវិញក្នុងការបោះពុម្ពផ្សាយ ផ្សព្វផ្សាយ ការសរសេរឡើងវិញ ឬ ការចែកចាយឡើងវិញ ដោយគ្មានការអនុញ្ញាតជាលាយលក្ខណ៍អក្សរឡើយ។
ស៊ីស៊ីអាយអឹម មិនទទួលខុសត្រូវចំពោះការលួចចម្លងនិងចុះផ្សាយបន្តណាមួយ ដែលខុស នាំឲ្យយល់ខុស បន្លំ ក្លែងបន្លំ តាមគ្រប់ទម្រង់និងគ្រប់មធ្យោបាយ។ ជនប្រព្រឹត្តិ និងអ្នកផ្សំគំនិត ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់កម្ពុជា និងច្បាប់នានាដែលពាក់ព័ន្ធ។

## អត្ថបទទាក់ទង

### សូមផ្ដល់មតិយោបល់លើអត្ថបទនេះ

នាម និងគោត្តម *
សូមវាយបញ្ចូលឈ្មោះរបស់អ្នក

អ៊ីម៉ែល *
សូមវាយអាសយដ្ឋានអ៊ីម៉ែលរបស់អ្នក...

លេខទូរសព្ទ (មិនចាំបាច់)
បើសិនជាអ្នកចង់ឱ្យខាងក្រុមការងារ វីអូឌី ទាក់ទងទៅអ្នក សូមទម្លាក់លេខទូរសព្ទ ...

មតិយោបល់ *
សូមបញ្ចេញមតិយោបល់សម្រាប់អត្ថបទខាងលើនេះ...

ចុចបញ្ជូន

**ព័ត៌មានថ្មីៗ** | **បោះឆ្នោត**




លោក ហ៊ុន ម៉ាណែត បដិសេធមិនបានចុះហត្ថលេខាជំនួសនាយករដ្ឋមន្ត្រីរឿងផ្ដល់ជំនួយដល់ប្រទេសតួកគីនោះទេ

១២ កុម្ភៈ ២០២៣ ម៉ោង ១៨:១២

ធនាគារជាតិព្រមានវិធានការច្បាប់លើម្ចាស់គ្រឹះស្ថានឥណទានទទួលយកអត្តសញ្ញាណបណ្ណឬសៀវភៅគ្រួសារពីកូនបំណុល



១២ កុម្ភៈ ២០២៣ ម៉ោង ១៣:១៤

ក្រសួងការងារថា ក្រុមហ៊ុន ខេមបូ ហ៊ែនសាំ យល់ព្រមទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារជូនកម្មករ




១១ កុម្ភៈ ២០២៣ ម៉ោង ១៦:១៣




VOD

VOD គឺជាស្ថាប័នព័ត៌មានឯករាជ្យដែលផ្ដល់ព័ត៌មាន ផលិតកម្មវិធីវិទ្យុ និងការផ្សព្វផ្សាយតាមរយៈគេហទំព័រអ៊ីនធើណេត។

info@vodhotnews.com

+៨៥៥ ២៣ ៧២៦ ៨៤៥ - លេខបន្ទាន់: +៨៥៥ ៩២ ៩២ ១៩ ០២ / +៨៥៥ ៦០ ៥០ ៥០ ៥០

ផ្ទះលេខ១៤A ផ្លូវ៣៩២ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

GET IT ON Google Play | Download on the App Store






© ២០២២ រក្សាសិទ្ធិគ្រប់យ៉ាងដោយ ស៊ីស៊ីអាយអឹម